# ទំនាយបណ្តាំប្រស្នា

## ពារសុក្រ–ពារសៅរ៍



រៀបចំផ្សព្វផ្សាយឡើងវិញ

និងថែរក្សាមរតកដូនតាដោយៈ ទំព័រនគរខ្មែរ

# ប្រវត្តិសាស្ត្រ ថ្ងៃសុក្រ

( ស្រង់ពីច្បាប់ដើម )

ខ្ញុំ គិន ណន ជាអ្នកចម្លងតមកទៀត ខ្ញុំសូមសរសេរតាមសេចក្ដីដើមរបស់គេ ដោយគ្មានហ៊ានក្លែងបន្លំដូចមានតទៅនេះ “ តាមដែលខ្ញុំបានឮគេនិយាយតៗមកថា ទំនាយនេះ មានអ្នកស្រុកពោធិចិនតុងម្នាក់ ដើរទៅវាលស្រែស្រុកនេះ ស្រាប់តែបានឃើញរបស់ទាំងនេះ គឺ ឆត្រច្រត់និងយាម ១ អ្នកនោះបានរើសយករបស់ទាំងនេះចេញពីយាមមកឃើញមាន អកកំពោរ ប្រណាកស្វាម្ន ត្បាល់បុក ហើយឃើញទាំងទំនាយប្រស្នានេះផងនៅជាមួយគ្នា យកមកមើលឃើញជាទំនាយដូច្នេះ ក៏នឹកអែងខ្លួនមិនរាជការ ហើយយកវត្ថុទាំងនេះទៅជូនសាលាស្រុក ជួនជាពេលនោះ លោកស័ក្តិ ៤ អ៊ុំ ទៅលេងទឹងចៅហ្វាយស្រុក និយាយរឿងរ៉ាវជម្រាបលោកហើយយកទំនាយនោះមកជូនលោកមើល លោកស័ក្តិ ៤ បានមើលហើយហូតទំនាយនេះទុក អ្នកខ្លះក៏សុំចម្លងពីលោក និងចម្លងតៗគ្នាមក រហូតដល់មានស្ទើរតែសព្វខេត្ត ។ ដោយតែទំនាយប្រស្នានេះពុំមានឈ្មោះអ្នកទាយដាក់នៅជាប់ផង ទើបពុំបានឲ្យឈ្មោះដូចពុទ្ធទំនាយ ព្រះរោងទំនាយ ឥន្ទទំនាយ គេនាំគ្នាហៅថា “ ទំនាយឥតឈ្មោះ ” ។

ឯរឿងទំនាយនេះ បើថាដោយខ្ញុំជាអ្នកចម្លងសរសេរ ( គ្មានឈ្មោះ ) ស្មានប្រហែលជាកើតនៅឆ្នាំ ច សំរិទ្ធិស័ក ព.ស ២៤៥២ ។

លុះមកដល់ឆ្នាំ ច អដ្ឋស័ក ព.ស ២៤៨៩ លោកអ្នកឧកញ៉ាសុន្ទរវារាជកិច្ច ខឹម _ ប៉ែន ជាអ្នកកាន់កាប់ការ ក្រសួងព្រះបរមរាជវាំង បានឲ្យចម្លងទុកឲ្យឈ្មោះថា សាស្ត្រាថ្ងៃសុក្រ ព្រោះសាស្ត្រានេះចេញពាក្យថា ថ្ងៃសុក្រពេញបូណ៌មីជាខាងដើម ។

( មិនឃើញឈ្មោះអ្នកតែងប្រវត្តិនេះទេ ។ យើងចម្លងចេញពីច្បាប់សរសេរ តម្កល់ទុកនៅក្នុងក្រុមជំនុំទំនៀមទម្លាប់លេខ ៥៤ - ០៤២ ជាច្បាប់ចម្លងពីលោកកែប ( ប៉ាង កែប ) ធ្វើការនៅមន្ទីរព្រះរាជពង្សាវតារក្នុងវាំង ) ។

ថ្ងៃ ២១ - ៦ - ៧២

ខ្ញុំ គិន _ ណន ចំចម្លងសាស្ត្រាថ្ងៃសុក្រ ថ្ងៃសៅរ៍ មកបោះពុម្ពបន្តមកទៀត ដោយមានគោលគំនិតធំៗ ពីរយ៉ាងដូចខាងក្រោមនេះ ៖

ទី ១- រក្សាទុកកុំឱ្យបាត់បង់ទៅផង ។

ទី ២- បំនាយប្រស្នានេះជ្រៅរកខ្ញុំគិតពុំយល់ ហើយខ្ញុំជឿថា ពិតជាមានកវីបណ្ឌិតណាមួយ គេអាចទម្លាយទម្លុះនូវប្រស្នាអាថ៌កំបាំងនេះបាន អាចយកសេចក្ដីដែលគេខំបំបែកបាននោះ មកបោះពុម្ពចែកជូនបងប្អូន ឬ និយាយប្រាប់គ្នីគ្នាឱ្យបានយល់ ទុកជាគ្រឿងចំណាំនូវហេតុភេទស្រុកទេសតទៅ ។

# សារស្តារថ្ងៃសុក្រ

## បទពាក្យ ៧

ថ្ងៃសុក្រពេញបូណ៌មីខែភទ្របទ    នៅក្នុងកំណត់ព្រះវស្សា
ឆ្នាំឆ្លូវត្រីស័កនក្សត្រា    សាសនាពីរពាន់ប្អូនរយឆ្លាយ ។
នឹងថ្លែងពីរឿងរាជបូរី    ក្នុងផែនដែនដីនគរអាយ
កកើតអស្ចារ្យផងទាំងឡាយ    ក្មេងក្លាយទាំងគ្រប់សព្វសេចក្ដី ។
តាំងតែអ្នកឆ្ងាយគេចូលមក    នៅក្នុងគោកធ្លករាជបូរី
កកើតជាហេតុភេទដែនដី    ទាំងមនុស្សប្រុសស្រីប្រែចិន្តា ។
បែរបែកបោះបង់បែបបុរាណ    គ្រប់ប្រាណពុំមានតាមតម្រា
សឹងគ្រេកដោយទ្រព្យគ្រប់រូបា    ពុំមាននរណាតាមសណ្ដាប់ ។
ទាំងនេះហេតុតែភេទសេមា    ព្រះពុទ្ធសាសនាប្រែក្រឡាប់
បណ្ដាលក្នុងចិត្តងងឹតអ័ព្ទ    យកខុសជាគាប់ក្រឡាប់ប្រែ ។
អ្នកប្រាជ្ញប្រាប់ទៅខ្មៅមិនតាម    មិនដោយទំនៀមទំនងខ្មែរ
ចចេសចិត្តឯងអាងពូកែ    ក្បួនតែមានគេមកនៅថ្មី ។
ខ្លះអាងខ្លួនឯងមានមាសប្រាក់    មានបុណ្យមានស័ក្តិជាមន្ត្រី
ហើយកើតធំចិត្តធំសម្ដី    ឥតបីឥតបើនឹងគណនា ។
តម្កើងខ្លួនឯងឱ្យគេខ្លាច    ពាក្យកោងពោងកាចទាំងឫកពារ
មិនកោតមិនខ្លាចចាស់ព្រឹទ្ធា    អាងមានទ្រព្យាជាទីពឹង ។
ខ្លះអាងខ្លួនឯងមានចំណេះ    ប្រាជ្ញាវែរចេះជជែករឹង
ជជែកយកឈ្នះឈ្លោះទទឹង    មិនមានរំពឹងគិតខុសត្រូវ ។

មានទ្រព្យគាប់ចិត្តស្ញឹតធ្វើបុណ្យ
ភ្លាំងភ្លើនភ្លេចគុណកប៏គុណឪ
គិតតែធ្វើស្រែនិងលក់ស្រូវ
ឯផ្លូវទៅសួគ៌មិនទឹកសោះ ។
នេះហើយជាកម្មអកុសល
មកផ្តល់ឲ្យគ្មានបុណ្យឡើងសោះ
បើខាងស៊ីផឹកនឹកទាំងអស់
នោះទើបស្រួលស្រស់គិតរាល់ថ្ងៃ ។
ខ្លះមានបុណ្យស័ក្តិមើលងាយសង្ឃ
ព្រោះសាងផាអង្គងផងថ្លើងក្រៃ
សំពះព្រះសង្ឃក្រែងថោកដៃ
ឆ្មើងឆ្មៃឆ្គួចរិសីយផងក្រៅសាសន៍ ។
មានបុណ្យប៉ុណ្ណឹងប្រឹងក្រអើត
ចំកោងស្ពួយស្អើតមើលអាកាស
ចង់ធំតែខ្លួនគ្មានគិតខ្មាស
ចោលសង្ឃបង់សាសន៍ថ្លៃឧត្តម ។
ដូនកាលត្រូវការដើរចូលវត្ត
ពាក់មួកបាំងឆ័ត្រធ្វើឫទ្ធម
ចូលក្នុងអារាមគ្មានអារម្មណ៍
អាងខ្លួនជាធំប៉ុណ្ណោះឯង ។
អ្នកអើយនោះហើយហោរពោភា
ទោសោយហោនាំវង្វេង
បង្វែរនាំចិត្តឥតគិតក្រែង
នេះហោវង្វេងក្នុងសាសនា ។
មនុស្សលោកឥឡូវក្រៅព្រមក្រឹត្យ
កើតមានទ្រុស្តចិត្តបីប្រការ
ចិត្តមួយមិនខ្លាចគ្រូអាចារ្យ
ចិត្តមួយគោរពកាយមិនខ្លាចចាស់ ។
ចិត្តមួយមិនខ្លាចម៉ែឪឯង
ឥតកោតឥតក្រែងវែងក្រឡាស់
ក្រឡាប់ក្រឡប់គ្រប់សព្វភាសន៍
រាល់រូបរាល់រាស្ត្រស៊ីវង្វេង ។
វិលវល់ក្នុងចិត្តគិតវិវរ
ព្រោះភេទនគរកើតហេតុព្រេង
ទើបមានអកុសលផ្ទេះពង
ក្លាយក្មេងវង្វេងវរចិន្តា ។
នេះហៅប្រែរាជ្យប្រែសករាជ
សិស្សសោតមិនខ្លាចគ្រូអាចារ្យ
ឯកូនមិនខ្លាចអ្នកមេបា
រីឯភរិយាមិនខ្លាចប្តី ។
កន្តុបមិនចង់ខ្លាចពស់វែក
សត្វក្អែកចង់ផល់នឹងដំរី
ដើមចេកប្រុងផលនឹងក្របី
រីត្រីចង់ផល់នឹងបក្សា ។
ហេតុភេទទាំងនេះកើតមានមក
នាំឲ្យជនយកជាកិរិយា
សឹងចោលសណ្តាប់ធ្នាប់មាត្រា
ទើបលោកឧបមាផ្ទេះនៃ ។
គោស្រុកទៅចូលឯហ្វូងស្វា
ឯឆ្មាបង់ផ្ទះទៅពឹងព្រៃ
មច្ឆាចោលបឹងទៅពឹងព្រៃ
ក្របីចោលត្រពាំងស្រឡាញ់ក្រែង ។
យកជាពំនាក់នៃអាត្មា
ភ្លើងឆេះកាលណាទើបស្ទះស្វែង
ភ្លើងឆាបរោលរាលដល់ខ្លួនឯង
ទើបចោលបឹងក្រែងមករកត្រពាំង ។

រាជហង្សហើរបង់ចោលសំបុក ហើរទៅយកកុកជាសម្លាញ់
ដល់មានព្រានព្រៃមកបរបាញ់ កុកសសស្រាញ់បើរចោលហង្ស ។
ម្លោះហើយសមនឹងអសាសូន្យ អន្តរាយខូចខ្ទួនទៀទាសបង់
ព្រោះព្រើលគំនិតចិត្តគិតចង់ សប្បាយទើបបង់ពីសំបុក ។
លង់លុះមានភ័យដូច្នេះឯង ទើបបានបើរស្វែងរកទីសុខ
រកទៅរកមកបានតែទុក្ខ ព្រោះបង់សំបុកបានអាត្មា ។
ហៃនែអស់ជនទាំងឡាយអើយ អ្នកអើយនេះហើយហៅឧបមា
ឧបមេយ្យឲ្យដឹងហេតុគ្រប់គ្នា ការរងវេទនាជាប្រាកដ ។
ព្រោះជនមានចិត្តជាវិបល្លាស សាងអកុសលក្រាសដោយសន្ធត់
លោភខឹងវង្វេងជាបែបបទ កំណត់ឥតក្រែងបានរវិត ។
គ្មានទីករលើកទៅបាននាយ គិតតែសប្បាយនៅលោកិយ
ចង់មានចង់បានហួសពេកខ្ទី មានអ្វីអួតហ្នឹងឥតគណនា ។
មានគោអួតគោពូកែគាប់ មានទ្រព្យអួតទ្រព្យប្រសើរជា
ចេះគួរអួតគួរឥតគណនា ចេះបៀអួតបៀឥតបើស្តី ។
មានកូនអួតកូនដោយដំណើរ មានភ្លើអួតភ្លើដោយខេត្រី
មានសេះអួតសេះឲ្យបានល្បី មានអ្វីអួតហ្នឹងឲ្យបានខ្ពស់ ។
នរណាដូច្នោះនោះលោកថា រឹងស៊ឹងមនុស្សាបហាឆោតហួស
សឹងលុះអំណាចខ្មៅជ្រួលជ្រួស ពីព្រោះមិនត្រូវគន្លងឡើយ ។
នែអ្នកទាំងឡាយចូរស្អាងចិត្ត ស្អាងកាយប្រព្រឹត្តទៅអ្នកអើយ
ត្បិតព្រះសាសនាជិតដល់ហើយ កុំធ្វើតោះតើយគួរឲ្យប្រឹង ។
ធ្វើបុណ្យធ្វើទានកុំរៀនខ្មៅ កុំកាចឃោរឃៅឆោតឆាប់ខឹង
ធ្វើចិត្តឲ្យធ្ងន់មន់ទើបនឹង បានជាពុំនឹងទៅបាននាយ ។
សេចក្ដីនេះក្រែងអស់អ្នកផង ពុំដឹងទំនងការសម្ងាយ
នូវអស់កិច្ចការផងទាំងឡាយ នៃនគរអាយកើតកូនខ្ទី ។
កូនមួយជាប្អូនមួយជាបង ដើរព្រេចព្រសងសាងបារមី
ឯអស់មហាជនទាំងប្រុសស្រី បានដឹងសេចក្ដីនៃសុខំ ។
ផ្កាលាន់ឯចុងពិក្ខុកណ្ដក អ្នកតាចាស់ស្រុកឧបជៃឃំ
កំគីសះឡើងពងលើកំពូលភ្នំ ភ្លេកសសម្ងំក្នុងគុម្ពព្រៃ ។

ពោធិព្រឹក្សរាបគល់ពុំចាក់ឫស　ពស់វែកត្រាំពិសផ្ទាំកន្ទែង
ក្របីលាក់ខ្លួនសម្រួចស្នែង　រាជហង្សហើរស្វែងកាច់សំបុក ។
ពពេចក្រាបពងក្រោមគង្គា　ក្អែកពាំផ្លែល្វារាយគ្រប់ស្រុក
អ្នកផងឃើញហើយប្រឹងរើសទុក　ចំណោរទោមុខទើបដឹងខ្លួន ។
ស្វាក្រេះក្រញឹងប្រឹងហាត់គុន　លុះឃើញសេះលុនទើបរត់ពួន
កុកសកវែងឯងអួតខ្លួន　ថាដឹងចំនួនត្រីក្នុងទឹក ។
កុកសាប់រកស៊ីកណ្ដាលត្រពាំង　សស្រាក់សស្រាញ់ពុំមានភ្លឹក
សីហនាទគគាតផាតទ្វីក　ចាប់ត្រីរាល់ព្រឹកគ្មានមេត្តា ។
ខ្លាញីរកស៊ីក្នុងសមសាន្ត　លាក់ប្រាណលំអានចាំសាសនា
លុះដល់ផ្លូវលាន់បួនទិសា　ទើបខ្លាយាត្រាពីក្នុងព្រៃ ។
ឱ្យអស់មហាជនស្រាយចំណោទ　ដែលខ្ញុំចែងចោទអាថ៌សេចក្ដី
បើអ្នកឯណាប្រាជ្ញាវៃ　ទើបដឹងសេចក្ដីនៃបញ្ហា ។
រីឯគោស្រុកនិងកុកស　សព្វថ្ងៃអបអរស្រឡាញ់គ្នា
ធ្វើហាក់ដូចមិត្តចិត្តស្នេហា　តែជាគំនិតគិតទិទៃ ។
ឯកុកនិងខ្លានៅដោយខ្លួន　មិនទាន់ជួបជួនគ្នាឡើយនៃ
តែជួបកាលណាអស្ចារ្យក្រៃ　សព្វសាសន៍ទិទៃភ័យមិនខាន ។
ត្បិតអ្នកទាំងពីរសឹងកាចក្ដាត់　អួតអាងអារុធតែរាល់ប្រាណ
កាន់ឫទ្ធិចេស្ដាពន់ប្រមាណ　សឹងកាចហាវហានឥតឧបមា ។
ឥឡូវខ្ញុំសួរអ្នកទាំងឡាយ　ស្ម័គ្រចិត្តស្ម័គ្រកាយទៅខាងណា
ជាស្ម័គ្រខាងកុកឬខាងខ្លា　អ្នកមានប្រាជ្ញាទើបថាត្រូវ ។
ឯមនុស្សរីឯស៊ុំអារាសែ　ឃើញតែគេខ្ពស់ដូច្នោះកូវ
ម្ល៉ោះហើយផ្ដេកខ្លួនចូលចិត្តទៅ　អែបអបនិត្យនៅធ្វើអាត្មា ។
នេះហើយសង្គ្រាមសករាជថ្មី　អ្នកល្បីនិងល្បីល្បែងចេស្ដា
ឯត្រង់ឈ្មោះចាញ់មិនបាំងថា　តែនឹងឧបមាដូច្នោះនៃ ។
កន្ដុបខ្លួនតូចទាបមេតើ　ផ្ទឹមម្ដេចឱ្យស្មើនឹងដំរី
កន្ដុបនៅតែដោយរូងដី　ផ្ទឹមម្ដេចរាជសីហ៍មានគុហា ។
អំពិលអំពែកតូចមួយមិញ　ម្ដេចឡើយគិតផ្ដាញ់ព្រះចន្ទ្រា
សត្វចាបខ្លួនតូចឥតគណនា　ម្ដេចឡើយពុះពារផល់នឹងមាន់ ។

រីសោតកុកសាប់អាប់វង្សា ម្ដេចមកប្រាថ្នាហង្សសោភ័ណ
សំណស្ងួលាយកាឡៃស្ពាន់ ផ្ទឹមម្ដេចសុវណ្ណមាសចរណៃ ។
ដូច្នោះអ្នកអើយចូរអ្នកគិត រំពឹងក្នុងចិត្តកុំសង្ស័យ
ពពួកកាឯខ្លាធ្លាប់នៅក្នុងព្រៃ កន្ទុយវែងវៃបំពេនទុក ។
ឥឡូវខ្លាដឹងដំណឹងជាក់ ថាគោបកស្ទូគ្រទាក់ទឹងកុក
វិស័យឯខ្លាទន្សាយស្រុក ដឹងហើយកើតទុក្ខ ឥតឧបមា ។
ផ្គរលាន់ឯជើងភ្លឹងនេះទឹក នេះដើមពោធិព្រឹក្សព្រៃបព្វតា
លុះដល់សៀលព្រះសូរិយា ទើបខ្លាយាត្រាលត់ភ្លើងព្រៃ ។
ហែអស់មហាជនទាំងឡាយអើយ អ្នកអើយដឹងហើយគួររំពៃ
រំពឹងរកបានខ្លួនទីទៃ អៀសវៃឱយឆាប់រ៉ា ។
សេចក្ដីនេះបានមែនពិតហើយ អ្នកអើយកុំកញ្ញទាល់ប្រាជ្ញា
រឿងនេះអ្នកប្រាជ្ញលោកឧបមា ឱយអ្នករាល់គ្នាគិតឱ្យយល់ ។
សាសនាពីពាន់បួនរយឆ្នាំ តាមដោយទំនាយព្រះទសពល
អ្នកបុណ្យចាប់ផ្ទៃក្នុងបណ្ដាល កើតកោលាហលខ្វល់ជំពាក់ ។
កើតកាប់លួចប្លន់ក្នុងនគរ សង្គ្រាមរឹករវគ្មានទីភ្នាក់
គ្មានទីអាស្រ័យជាពំនាក់ ពំនឹងពឹងពាក់អាត្មាឡើយ ។
អ្នកអើយឮហើយគួរភាវនា ធ្វើបុណ្យគ្រប់គ្នាកុំកន្ដើយ
សីលទានភាវនាធ្វើឱ្យហើយ ទើបអ្នកបានស្បើយពីទុក្ខភ័យ ។
ការនេះអ្នកប្រាជ្ញអាចប្រាយប្រាប់ ឱ្យអ្នកផងស្ដាប់ហើយរវៃ
អៀសសាងមគ្គផលប្រពៃ ដើម្បីឱ្យទាន់ព្រះសិអារ្យ ។
ហែអស់មហាជនផងទាំងឡាយ កុំភ្លេកភ្លើនកាយភ្លេចមាតា
ភ្លេចភ្លាំងគុណគ្រូគុណអាចារ្យ ទាំងគុណបិតានឹងគុណបង ។
តែភ្លេចសឹងភ្នាត់ក្ដីប្រាថ្នា ភ្លេចនេះហៅមហាខុសពេកហោង
អ្នកណាធ្វើតាមដោយគន្លង នេះហោងនឹងបានដូចប្រាថ្នា ។
ឥឡូវនេះសឹងបង្អង់ស្ទេះ បញ្ឈប់បុណ្ណេះពុំចរចា
សព្ទួបសេចក្ដីនៃប្រស្នា សូរេចប់ការម៉េះឯងហោង ។

*សុភាសិត*

ទាហានថ្កើងត្បិតសឹក
ធ្វើស្រែត្បិតទឹក
ត្រឹកពលព្រោះបាយ
សិស្សប្រាជ្ញត្បិតគ្រូ
ជេរពោលដំរាយ
ពលថ្កើងត្បិតនាយ
ហ្វ៊ាហ្វឹនខះខំ ។

( ច្បាប់រាជនេតិ )

# សាស្ត្រាល្បើកថ្ងៃសៅរ៍

# ឬ

# សាស្ត្រាពារៈសៅរ៍

## បទពាក្យ ៧

ពារសៅរ៍ពេញ បូណ៌ខែកត្តិក
ចេញខ្ញុំលុះអ៊ឹកពីនគ្គា
ត្រូវផាត់សុខស្បិបរស់កាយា
រាគាមំរើយហើយផាត់ ។
ទៅក្នុងហិមន្តរដូវ
ឆ្នាំខាលនោះក្រុវត្រូវឯកស័ក
ព្រះសូរ្យចាំងចែងត្រូវក្តៅកាត់
ត្រីចះប្រែ ចាំរកទឹកជ្រៅ ។
ចង្វាផ្អើលផ្ញើមផល្អិមប្រូក
ត្រីចុះកុះករកលំនៅ
ឆ្ងៀរ រៀលរកទឹកអប្បៅ
សំរោរុះរកព្រៃតមិទៃ ។
សូរិយាទៀបចមិមចះម្អុះត្រុំ
ពួមាត់សេកហើរពងព្រៃ
លលក ធំលើចុងឈើរលៃ
រងាវខ្ទវ៉ៃក្រៃពួលទ្វាច ។
មើលបាននទឹមត្រឹបលទ្ធំ
រលើឈឈ ខ្ពស់ខ្ពង់ត្បូស្រលោច
ស្រងាត់ក្នុងចិត្តគិតផ្សារខ្វាច
កណ្តើះកណ្តោចកណ្តាលបាន ។
គន់មើលទៅវាលៗ រីវេក
វែងធំរើក ពេកពន់ប្រមាណ
មើលសត្វវែងថប់អាណិតប្រាណ
ព្រោះដោយឃ្លាតបានទឹកថ្លេង ។
ពេលព្រឹកមើលមេឃមីរកងឹត
ពពកលល សិតរុំជុំផ្សេង
ថ្ងៃត្រង់ក្រលូកព្រះសូរ្យសែង
បក្សីហើរស្វែងចុះចិនជ្រៅ ។
ពិរុណរាំងរឹងវែងហែងហួត
គោរកទឹកកក់ស្អួតត្រប់លំនៅ
ស្រូវលោស់ផ្កាំ ខៀវខ្ចីខ្មៅ
ទឹកហុ ចះទៅតាមផ្រលង ។
មើលសត្វប្រវាត់ហើរខៀវខ្វារ
ស្វែងរកមច្ឆាទោះឡោកង
ពួសពួយក្រែសកស្វារពង
ហើយហើរត្រសងដោយហ្វូងវា ។
គន់មើលទៅសត្វវែងសញ្ជប់
រំពឹងគិតគ្រប់ផើលមេឃា
ឃើញហើយទឹកដល់ក្តីវេទនា
ដោយខ្លួនព្រាត់ព្រាត់ពង្វែង ។
មើលស្រុកមើលស្រែប្រែទាំងគ្រប់
ក្នុងផែនដីភពក្រៅនេះផង
គន់មើលសព្វា ថបបំបែង
គិតព្រួងព្រៀបប្រៀមិនបានឡើយ ។

ត្បិតមើលទៅផនផងចាំងឡាយ    សឹងតែប្រែក្លាយទោរស់ហើយ
មិនគង់កំណត់ដូចដើមឡើយ    នឹកហើយវែងថប់ពន់ប្រមាណ ។
ហេតុដោយវេរារាត្បៀសករាជ    អ្នកខ្លាមិនខ្លាចអ្នកប្រាជ្ញប្រាណ
បក្សាវែងជាស្អប់សមសាន្ត    មនុស្សលោកក្អួចបានស្អប់ព្រៃព្រឹក្ស ។
វិក្ខនមិនខ្លាចអ្នកមេធា    វែមហាក្សត្រាមិនជឿឫក្ស
ហោរាមិនជឿរាជបណ្ឌិត    អាចារ្យព្រាគព្រឹម្ទមិនជឿបុណ្យ ។
វិសិស្សមិនជឿគ្រូអាចារ្យ    ក្នុងចិត្តគិតថាគ្រូគ្មានគុណ
វឹងពេទ្យហ្លួមិនជឿមន្ត្ត    បមហាជនឥឡូវដូច្នេះឯង ។
នេះហើយហេតុតែព្រះសាស្នា    ប្រែភេទក្រឡាឡូវភ្នែង
វិលវល់ក្នុងចិត្តឥតគិតក្រែង    បង្វែងឱ្យវក្នុងចិន្តា ។
យកខុសជាត្រូវ ៗ ជាខុស    សេចក្តីដូច្នោះហេតុសាស្នា
កើតក្នុងគន្លល់រាជសីមា    អស្ចារ្យទាំងគ្រប់សព្វសេចក្តី ។
អ្នកខ្លះមានទ្រព្យគាប់ចិន្តា    ហើយមិនប្រាថ្នាសម្បត្តិបី
គិតឃើញតែក្នុងនាលោកិយ    ទាំងប្រុសទាំងស្រីសិងដូចគ្នា ។
មានទ្រព្យគាប់ចិត្តស្បិតធ្វើបុណ្យ    មិនមានគិតគុណគ្រប់ប្រការ
តម្កើងចង់ធំតែអាត្មា    ក្នុងចិត្តគិតថាអញថ្កើងហើយ ។
ខ្លះអាងយសសក្តិមាក់ងាយសង្ឃ    ក្នុងចិត្តមិនចង់កោតខ្លាចឡើយ
បើធ្វើការបុណ្យនឹងគេហើយ    ព្រងើយកន្តើយមិនឧហាត ។
ប្រើគេប្រើឯងមិនក្រែងចិត្ត    ព្រោះដោយគំនិតគិតប្រមាថ
ធ្វើបុណ្យធ្វើទានគ្មានសង្វាត    ដោយខ្នាតព្រះពុទ្ធនោះគ្មានសោះ ។
ធ្វើបន្តិចបន្តួចចង់ធំមុខ    តែងតួលើកទុកឱយថ្កើងខ្ពស់
មិនឱ្យនរណាស្មើខ្លួនសោះ    ស្មើហើយគិតឈ្លោះអាក់ចិន្តា ។
មនុស្សខ្លាលោកហោរង្វេងវណ្ណ    ស្រឡាញ់ទ្រព្យធនលើសអាត្មា
ស្រឡាញ់នរកលើសសួគ៌ា    ព្រោះដោយកាមាទាំងងងឹត ។
ងេងងោងក្នុងកាយស្មាយទាំងគ្រប់    វង្វេងងោកងប់មិនមានគិត
ចង់ឱយបានថ្កើងខ្ពស់ដូចចិត្ត    ហេតុដោយងងឹតក្នុងអវិជ្ជា ។
មានគោអួតគោពូកែគាប់    មានទ្រព្យអួតទ្រព្យប្រសើរជា
ចេះផាងអួតផាងឥតគណនា    ចេះបៀអួតបៀឥតបើស្តី ។

នេះហើយហៅហេតុតែលោភា ទោះសោរចោរហាអន្សុំរៀប
មកនាំឱ្យធ្លាក់ក្នុងលោកិយ ឥតបិឥតបើភ្លេចតិចឡើយ ។
ភ្លេចសីលភ្លេចទានភ្លេចគុណទោស ភ្លេចបាបភ្លេចបុណ្យសូន្យអស់ហើយ
បង់ចោលព្រះធម៌ចេញកន្តើយ អ្នកអើយនេះហើយហៅវង្វេង ។
មនុស្សយើងឥឡូវត្រូវបានគេ ចូលមកជាមេធំចិញ្ចឹង
ទោលសាសន៍ស្រឡះពីសាសន៍ឯង អ្វីៗទន្ទេងនាំចូលដែរ ។
កើតហេតុតិចតួចផ្តួចផ្តើមឡើង ចចេសចចើងអួតពូកែ
មិនមានគិតគុណត្រកូលខ្មែរ នេះហើយហៅប្រែគោលាហល ។
អនិច្ចារូបអើយរាល់តែកាយ ដែលកើតដែនអាយអកុសល
រំពឹងគន់គិតសែនថប់សល់ ព្រោះដោយមណ្ឌលមកកើតភេទ ។
ភេទអើយកើតមកពីឯណា កើតពីអាត្មាឯងមែនពិត
ពឹងគេលលើធ្វើជាមិត្ត មិនមានហៅគិតឱ្យវែងឆ្ងាយ ។
គន់មើលសាសន៍ឯងវង្វេងអស់ មិនសល់មួយសោះសូន្យសព្វសាយ
ថាបើដូចនោះអ្នកទាំងឡាយ ចូរស្តាប់បរិយាយអ្នកប្រាជ្ញប្រាប់ ។
✱ឱ្យដឹងពីទីរាជក្រុងព្រៃ គោកធ្លកវិជ័យដោយក្បួនច្បាប់
ហៃអ្នកទាំងឡាយចូរចាំស្តាប់ អ្នកប្រាជ្ញអាចប្រាប់ដោយទំនាយ ។
ដំណើរអំពីបូរីមន្យ ខុសក្រោត្រើស្បក្រមក្បួននិយាយ
រលៀងយៀងពីពុទ្ធទំនាយ ព្រះឥន្ទ្រលោកទាយក៏មិនត្រូវ ។
ព្រោះដោយនរកកើតមានកម្ម ពីទាយមកនាំផ្ទុះចេះកូរ
មកកើតវិវាទគ្រាឥឡូវ កម្មគេឱ្យត្រូវផ្ទុះចេះឯង ។
ហៃអ្នកទាំងឡាយចូរស្តែងស្តាប់ អស់អាថ៌សារស័ព្ទសេចក្តីថ្លែង
ន័យនេះអ្នកចេះលោកចាត់ចែង ចំណោទថ្វាថ្លែងឱ្យបានដឹង ។
អស់អាថ៌កិច្ចការក្នុងបុរី ទើបចែងសេចក្តីជាដំណើង
ចំនងឱ្យអស់អ្នកផងដឹង គ្រាហ្នឹងទើបចែងជាប្រស្នា ។
តាមដោយប្រាជ្ញប្រាណបានដឹងន័យ កិច្ចការទីទៃក្នុងសីមា
កើតមានហេតុភេទគ្រប់រូបការ អ្នកណាកាត់យល់មានព្រេងធំ ។
ផ្តាលោវាន់ឯបូពីស្រុកណ្តូក អ្នកតាចាស់ស្រុកឪបដែយំ
កំពឹសឡើងពងលើកំពូលភ្នំ ក្អែកសសម្ងំក្នុងគុម្ពព្រៃង ។

ស្រាកត្រាំត្រូវកំពង់តែចាក់ឫស
ពស់វែកមានពិសដ៏កន្ទ្រាំង
ត្រឡប់លាក់ខ្លួនសម្រួចសេង
លុះទឹកលិចព្រៃទើបចេញវាល ។
កង្កួយអាចម៉ះតាមឡោះពោះធំ
រលឹកព្រួយភ្នំធំត្រូវកាល
ថ្លើងក៏ទ្រើតផ្លើងសត្វស៊ែរតែត្រូវសាល
ចំរើនបីលវាលរោយតំណាក្ត ។
ដំរីនោងទត់កន្ទុមាក់
ឃើញមួបត្រជាក់សំណាក់ព្រាណ
ចំរើចរំពេលវេលាបាន
ទើបចរចេញថ្នានមួបនោះឯង ។
ក្អែកហើរមកពីឧត្តរ
ជួបនឹងក្អែកស្មកូចត្បូងព្រៃង
បបួលគ្នាពោះហើរស្វែង
រកទឹកខ្វែងបេងចីថៃ ។
ពពេចពុតឆ្អើរហើរទៅក្បួន
ខ្លាធំលាក់ខ្លួនពួនក្នុងព្រៃ
ពពេចចូលព្រែកក្រោមដើមព្រៃ
ផញ្ចប់ទាំងថ្ងៃទើបវិលា ។
ត្រីក្រាញ់ក្រញ៉ូញត្រោបក្រោមបាតភ្នំ
ត្រីកន្ធុយសម្ងំក្រោមត្បូងក្ដា
ខ្លាខ្លាក់ងឹតកុំចាធា
ក្រចកជើងរាក្រោយក្តិបដី ។
បីពធំក្រពែតកណ្តាលព្រៃ
សព្វសត្វទទៃស៊ីឥតពីងពាក់
អាស្រ័យសព្វព្រៃផ្លាពាក់ទាក់
ព្រោះដោយត្រជាក់សុខសប្បាយ ។
ឥឡូវទីទីបែងហួតអស់
ត្រីទឹកស្រែណោះអាណិតណាយ
ព្រោះដោយក្បុក្រក្របកាំចាយ
ក៏ចាត់ចរបក់ការជាចំណើ ។
ក្អែកតាវផ្លូវល្អរាយគ្រប់ស្រុក
អ្នកតាក៏ទុក្ខមិនចេញស្តី
ចង្ក្រាប់ផ្លូវបោះទិសប្រាំបី
លាន់ឮក្រោមដីផ្ទុះគណ្តូក ។
រាជហង្សហើយចាំចោលសំបុក
ហើយទៅរកក្ដុកនិងសក្ខាញ់
លុះមានព្រានព្រៃឈរបាញ់
ក្ដុកសសោតចេញហើរចោលហង្ស ។
ម៉េះបើយេសមនឹងអសារស្ទៀ
អន្តរាយខូចខ្ទេចវិនាសបង់
ព្រោះដោយគំនិតគិតចង់ចង់
ឡូមានក្តីអន្តក្នុងលោកិយ ។
មនុស្សស្រណោះតែពោកឆ្កួត
ពីដើមរៀងមកគ្មានព្រួយអ្វី
ឥឡូវស្មាតីលើឃ្មាងបី
អ្នកស្រុកប្រុសស្រីស្តីដើមពង ។
ពានរចាប់ភ្លួនផុនទុព្វទ្រា
ស៊ីជាអាហារសប្បាយទោង
មិនមានអាណិតគិតកូនព្រៃ
ហេតុដោយស្តេងភ្លេចញាណ ។
ចរ្ការនាស្ងួរការសីហ៍សត្វ
ម្ដេចឡើយព្រែកផ្ដាច់កាប់ស្វាន្ត
មិនឃើញអ្នកបកចេញទូន្មាន
ឬអាក់អន់ចិត្តជឿដំណើរអ្វី ។

ថ្ងៃមួយឃើញបឹងរីងហែងហួត　　ពិរុណរាំងស្ងួតវិនាសត្រី
ប្តូរឃើញស្មាគិរះឃ្លោះដប៊ី　　ទើបបានអ្នកថ្លែងមិនចេញមក ។
បាត់សូន្យយ៉ាងហ្នឹងដឹងយ៉ាងណា　　ឬចាំមោចារ្យទោតាយក
ឬមួកាគ្នាចម្ងប់ដឹងឈប់ជ្រក　　ទើបតែវពន្ធកមិនមាសអាយ ។
ម្ដេចអ្នកមិនអាសូរសព្វសត្វ　　រង់ចាំពេញភ្នាក់លំបាកកាយ
សព្វថ្ងៃគ្មានសោះពៅសប្បាយ　　ព្រួយណាស់ហើយណាយឥតឧបមា ។
វិហារធំវាំងឡាយចូរស្តែងស្តាប់　　អស់អាថិសារសត្វ៍គ្រប់ប្រការ
ពីរោគអ្នកប្រាថ្នាចែងចរចា　　ចោទចង់ប្រស្នាដោយប្រាថ្នាប្រាណ ។
ព្រោះដោយបានដឹងដំណឹងច្បាស់　　ប្រាកដជាក់ណាស់ទើបធិទាន
ឱ្យអស់អ្នកផងមើលបានហ៊ាន　　អ្នកអើញគ្រប់ប្រាណស្តាប់ប្រស្នា ។
នេះឯងខ្ញុំយើងបានច្បាស់ជាក់　　បើដឹងហើយអ្នកកុំចរចា
រង់ចាំមើលទៅតាមសាសនា　　ធម្មតាសាសនាខ្មែរមិនសូន្យ ។
វិស័យស្រមោលមិនចោលប្រាណ　　ស្រីផ្កាះក្នុងបានមិនបង់ខ្លួន
វិញផ្កាមិនចោលក្លិន　　មាតានិងកូនមិនដែលបង់ ។
អ្នកអើយឮហើយគួររំពឹង　　ទុកចិត្តឱ្យនឹងទាត់ទៀងត្រង់
ណា ៗ អ្នកកុំចោលព្រះសង្ឃ　　ខ្ញុំឃ្លាតគម្រង់កុំតាមគេ ។
ត្បិតរាជឥឡូវខុសសណ្ដាប់　　ក្រពើលង់ស្លាប់ក្នុងទន្លេ
បក្សាខ្លាចបឹង អ្នកដឹងទេ　　កូនខ្លាខ្លាចមេភេខ្លាចត្រី ។
អន្លង់ខ្លាចភក់កុកព្រឺបឹង　　ស្វាក្រេះក្រញីងចះស្រដី
ឈើធំមួយដើមបង្គោងចី　　ថិរាប្រុសស្រីស្រឡាញ់ប្រែត ។
សំបកឃ្លោកលិចក្នុងទឹកស្រែ　　អំបែងបែកប្រែជាអណ្តែត
នេះហើយហៅកើតកោលាភព　　ផ្ការលាន់ខែចេត្រភ្លៀងលិចស្រុក ។
លិចស្រែចំការច្បារដំណាំ　　លិចព្រែកទាំងប្រាំត្រពាំងថ្លុក
ទើបត្រីទាំងឡាយសប្បាយសុខ　　សៀមទុក្ខរីកមុខដោយសារភ្លៀង ។
ភ្នែះភ្នំបំផ្លុងកណ្តាលព្រៃ　　រោលរាលផល់នីយស្រីមានរាង
សំពត់ពេញដីស្រីមិនលាង　　ព្រោះវាឃើញទឹកភ្លៀងពីលើភ្នំ ។
សេចក្តីចំណោទអស់នេះណា　　ចែងតាមប្រាថ្នាគិតផ្ទៀងផ្ទាំ
លើកតាមហេតុភេទបុរាណ　　កើតខុសក្រឹត្យក្រមទំនៀមខ្មែរ ។

ជំពូកមួយទៀតខ្ញុំនឹកថា
ក្រែងមានលោកណាប្រាជ្ញាពូកែ
សាសន៍ខ្មែរដូចគ្នានឹកមិនស្អប់
ទើបបានជាខ្ញុំសុំប្រដៅ
ត្បិតឃើញចម្លែកក្រៃពេកពន់
មិនមានអារម្មណ៍ពិចារណា
មានខ្លះនិយាយនឹងព្រះសង្ឃ
មានកាលកំហល់ស្រែកកំហែង
ឃើញលោកអំណត់អត់មិនថា
ធ្វើឫកធ្វើពារជាអ្នកកាច
ឃើញគេមានបក្សគួរសមសួន
ឯងច្រណែនខ្នាញ់នៅក្នុងពោះ
ខ្លះឃើញគេមានរបស់ទ្រព្យ
ឯងនឹកច្រណែននិន្ទាគេ
នេះឯងមោហោទាំងផិត
ដូច្នេះអ្នកអើយបើមិនដឹង
តែងតាមចិទ្វេសដោយចំនង
ចិត្តកើតបណ្ដាលហេតុឱ្យមាន
ដែលកើតលោភោទាំងផិត
ភ្លេចបងភ្លេចប្អូនសូន្យក្នុងកាយ
គិតឃើញតែស្ដាយគ្រប់ប្រការ
កង្វល់ខ្វល់ខ្វាយឆ្ងាយមិនគិត
នេះគឺជាកម្មមកបាំងបិទ
រិលរល់មិនយល់គ្រប់ប្រការ
អ្នកខ្លះភ្លេចគុណអ្នកមែឪ
បោះបង់មិនចង់ឱ្យមកជិត
មានទ្រព្យច្រើនហើយក្រវើនទុក
ធ្វើវត្តបដិបត្តិសោតណាសល់

ចង់ដឹងប្រាជ្ញាអ្នកស្រុកស្រែ
អាចកត់បកប្រែស្រាយដឹងខេវ ។
ឃើញហើយខ្ញុំចប់កើតហ្មងសៅ
រំលឹកឱ្យត្រូវតាមបាត្រា ។
មានខ្លះធ្វើបុណ្យហើយផឹកស្រា
តាមតែចិន្ដាអាត្មាឯង ។
ពាក្យស្មើពុំចង់ភាគខ្លាចក្រែង
អ៊ុអើអញឯងអាងអំណាច ។
កើតក្នុងចិន្ដាថាលោកខ្លាច
មាក់ងាយអ្នកប្រាជ្ញមិនមានខ្មាស់ ។
គ្រាន់បើជាងខ្លួនដោយសក្ដិយស
ប្រឹងលើកខ្លួននោះឱ្យដូចគេ ។
អ្នកផងតែងរាប់ទុកជាមេ
លបល្បួចស្ដីជេរដោយសារខឹង ។
រង្វេងក្នុងចិត្តឱ្យដូចហ្នឹង
ចូរស្ដាប់ដំណឹងខ្ញុំទិទាន ។
ដំណើរដើមចងមនុស្សល្ងានពាន
គ្រប់ប្រុសគ្រប់ប្រាណដែនដីកាយ ។
ភ្លេចគុណភ្លេចគិតឪពុកម្ដាយ
ភ្លេចសព្វសីលសាយកាយសុចរិត ។
នេះហើយហេតុជាកម្មនាំចិត្ត
ងងល់ងងឹតគ្រប់ប្រការ ។
ឱ្យខ្វល់ងងឹតដូចនេះណា
សូម្បីសព្វសញ្ញាមហាងងឹត ។
ឃើញចាស់សក់ស្កូវរោគរោយរឹត
ព្រោះដោយគំនិតគិតខ្លាចខាត ។
ធ្វើមានទោមុខកោលាហល
ហើយរក្សាដល់ភ្នក់ពីរហោង ។

រីអ្នកម៉ែឪត្រូវចាស់ ។
ឃើញកូនមានទ្រព្យមកនៅផង
នៅផ្ទះខ្ជិលណាស់មិនមេត្តា
ម្ល៉េះហើយផិនខ្លួនពន់ប្រមាណ
មានកាលបើបានចំណីឆ្ងាញ់
បញ្ជោះឲ្យទៅទាំងខ្ជីខ្ជា
ឃើញចាស់នៅខ្ទក់ខ្នាញ់ក្នុងចិត្ត
ស្តីទាយស្តីអាយដោយប្រាជ្ញា
រីខ្ញុំធីងនិទានតែងសេចក្តី
តិះព្រោះគ្រាន់មើលលងប្រាជ្ញា

ពិបាកពេកណាស់ពន់កន្លង
ឯកូនសោតហោងមេត្តាគ្មាន ។
ដេកលើដោយសារកម្លាំងប្រាណ
ខេទឹងមិនខានមួយវេលា ។
ក្នុងចិត្តនោះមិញទឹងមហិមា
សម្តីគរកៀរកែកលថា ។
ធុញថប់គំនិតគ្រប់ប្រការ
ព្រោះដោយចិន្តាចង់បានមាន ។
ពុំសូវគេច្បីដោយវោហារ
ប្រាជ្ញាសង្ខេបប៉ុណ្ណោះហោង ។